# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ហង់ អួយ ភេទប្រុស (បាត់ខ្លួន) K07614
## គួនាទីប្រធានពេទ្យចក្រកែវភ្នំពេញ
## ជួបសម្ភាសជាមួយ អួ លាង អាយុ៤០ត្រូវជាប្អូនស្រី
## រស់នៅភូមិវាល ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល
## នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣
## សម្ភាសដោយៈ ផាន់ សុខជា

សុជាៈ អត់ទោសមីងឈ្មោះអីដែរមីង?

លាងៈ ខ្ញុំឈ្មោះអួ លាង ។

សុជាៈ មីងអាយុប៉ុន្មានដែរ?

លាងៈ ៤០ ។

សុជាៈ ៤០គត់?

លាងៈ ចា៎ ។

សុជាៈ មីងមានបងប្អូនប៉ុន្មាននាក់?

លាងៈ បងប្អូន៩នាក់ ។

សុជាៈ ឪពុកមីងឈ្មោះអីដែរ?

លាងៈ ឈ្មោះហង់ អួ ។

សុជាៈ ចុះម្តាយ?

លាងៈ ឈ្មោះ សំ លន់ ។

សុជាៈ ចុះមីងមានស្រុកកំណើតនៅខាងណាដែរ?

លាងៈ នៅភូមិវាល ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។

សុជាៈ មីងធ្វើការរស់ស៊ីអីដែរ?

លាងៈ ធ្វើនំលក់បន្តិចបន្តួច ។

សុជាៈ ខ្ញុំចង់សួរពីបងមីងឈ្មោះហង់ អួយ?

លាង៖  ហង់ អួយ ។

សុជា៖  គាត់កើតនៅក្នុងឆ្នាំណា?

លាង៖  អត់ចាំផង ប៉ុន្តែគាត់បងគេបង្អស់គាត់ឆ្នាំម្សាញ់ ។

សុជា៖  បើមកដល់ឥឡូវគាត់អាយុប៉ុន្មាន?

លាង៖  គាត់ប្រែប៩០ជាងហើយ ។

សុជា៖  គាត់កើតជានៅឯណាដែរ?

លាង៖  គាត់កើតនៅភូមិវាលណឹង ។

សុជា៖  គាត់មានបានរៀន បានអីទេ?

លាង៖  គាត់រៀនថ្នាក់ទី៦ពីសង្គមចាស់ ។

សុជា៖  គាត់រៀននៅឯណា?

លាង៖  គាត់រៀននៅនេះ នៅវត្តដែរណឹង ។

សុជា៖  វត្តអីគេណឹង?

លាង៖  វត្តស្ពានស្រែ ។

សុជា៖  ចុះក្រោយមកទៀត?

លាង៖  ក្រោយមកទៀតគាត់ចូលធ្វើកងទ័ពអី ។

សុជា៖  គាត់ចូលឆ្នាំណា?

លាង៖  ឆ្នាំ៧០ ។

សុជា៖  កាលណឹងគាត់អាយុប៉ុន្មាន?

លាង៖  កាលណឹងមិនដឹងអាយុប៉ុន្មានទេខ្ញុំនៅតូចៗដែរ ។

សុជា៖  ហេតុអីបានគាត់ចូល?

លាង៖  គាត់ចូលគេធ្វើចលនាតាមភូមិ តាមឃុំឲ្យធ្វើកងទ័ពដើម្បីវាយលន់ ណុលនោះ ។

សុជា៖  ខាងណាគេមកធ្វើចលនា?

លាង៖  ខាងសម្តេចឪណឹង ។

សុជា៖  ហើយកាលណឹងប្រធានភូមិ ប្រធានឃុំណឹង រឺក៏មានគេមកពីលើ?

លាង៖  មានគេមកពីលើ ។

សុជាៈ កាលណឹងគាត់ស្ម័គ្រចិត្តចូលរឺក៏?

លាងៈ គាត់ស្ម័គ្រចិត្ត ។

សុជាៈ ចុះឪពុកម្ដាយមីងគាត់មានអារម្មណ៍យ៉ាងម៉េចដែរ?

លាងៈ អត់មានអារម្មណ៍យ៉ាងម៉េចទេឲ្យកូនទៅ ដើម្បីរំដោះជាតិ ។

សុជាៈ ចុះកាលណឹងបងប្អូនមីងផ្សេងទៀតមានទៅទេ?

លាងៈ មានតែខ្ញុំហើយបងខ្ញុំម្នាក់ទៀតទៅ ។

សុជាៈ តែមីងទៅដំណាលគាត់?

លាងៈ ខ្ញុំទៅក្រោយគាត់ ។

សុជាៈ ទេក្រោយអូយណឹងទេ?

លាងៈ ចាំ ហើយបន្ទាប់មកបងខ្ញុំនៅធ្វើនៅ៣៣នោះ បងស្រីដែរ ។

សុជាៈ ៣៣ណឹងអីគេ?

លាងៈ ៣៣ស្រុកអីលិចនេះ ។

សុជាៈ ស្រុកអីណឹង?

លាងៈ ស្រុកនៅផ្លូវជាតិលេខ២ មុំផ្លូវជាតិលេខ២ ។

សុជាៈ ស្រុកបាទី រឺអី?

លាង ណឹងហើយស្រុកបាទី ណឹងហើយ ។

សុជាៈ ខេត្តតាកែវ?

លាងៈ ចាំ ហើយបន្ទាប់មកបានខ្ញុំ ។

សុជាៈ មីងចូលនៅឯណា?

លាងៈ ខ្ញុំចូលនៅស្អាង ។

សុជាៈ ចុះបងមីងឈ្មោះអូយនេះគាត់មានឈ្មោះផ្សេងទៀតទេ?

លាងៈ គាត់ឈ្មោះ ហង់ គីម អាណឹងគាត់ដាក់ឈ្មោះថ្មី ។

សុជាៈ កាលគាត់ទៅណឹងអាយុប៉ុន្មាន?

លាងៈ បែបអាយុ២០ហើយ ។

សុជាៈ កាលណឹងឆ្នាំ៧០?

លាង៖  ឆ្នាំ៧០ ។

សុជា៖  គាត់ចូល ៗនៅឯណា?

លាង៖  គាត់ចូលនៅតំបន់ កងតំបន់ ។

សុជា៖  តំបន់អីគេ?

លាង៖  តំបន់២៥ កាលណឹងគេហៅតំបន់២៥ តំបន់៣៣អាណឹងទៅផ្លូវជាតិលេខ២ ។

សុជា៖  គាត់ចូលទៅ ទៅតំបន់តែម្តងអត់មានចូលនៅភូមិឃុំយើងនេះទេ?

លាង៖  អត់ទេ ។

សុជា៖  កាលណឹងធ្វើអីទេ?

លាង៖  កងទ័ព ៗតំបន់ ។

សុជា៖  មូលដ្ឋានគេនៅកន្លែងណា?

លាង៖  នៅកោះធំ នៅច្រើនកន្លែងណាស់នៅកោះធំនៅព្រែកអំបិលអាណឹងមូលដ្ឋានទ័ពតំបន់គេ ។

សុជា៖  ហើយមីងមានដឹងពីណាគេប្រធានគាត់ទេ?

លាង៖  ឈ្មោះឆេង ។

សុជា៖  ឈ្មោះអីឆេង?

លាង៖  អ៊ូ ឆេង ។

សុជា៖  គាត់អ្នកស្រុកឯណា?

លាង៖  គាត់មិនដឹងនៅស្រុកណាទេ ប៉ុន្តែមេគេ ។

សុជា៖  យ៉ាងម៉េចបានមីងដឹងថាមេគេ?

លាង៖  ខ្ញុំ គាត់មកនិយាយប្រាប់ទៅខ្ញុំចាំ ។

សុជា៖  ឧស្សាហ៍មកលេងផ្ទះទេពេលគាត់ទៅ?

លាង៖  ឧស្សាហ៍ គាត់ឧស្សាហ៍ ។

សុជា៖  កាលគាត់ទៅណឹងគាត់ការហើយ រឺនៅ?

លាង៖  នៅគាត់នៅក្មេងណឹង អាយុ២០ ។

សុជា៖  ពេលគាត់ធ្វើទ័ពណឹង គាត់មាននិយាយថាគាត់ធ្លាប់ឡើងសមរភូមិទេ?

លាង៖  គាត់ឡើងសមរភូមិវៃណឹងគាត់ត្រូវគ្រាប់ឡើងសុះខ្លួន វៃព្រែកតូចវៃទៅខ្ទមសំណរ ទៅ

អ្នកលឿន  អាណឹងសុទ្ធតែគាត់ផ្នែកកងតំបន់ ។

សុជា៖  ចុះក្រោយមកទៀតគាត់ឡើងពីកងតំបន់ទៅដល់ណា?

លាង៖  ក្រោយទៀតគាត់ទៅពីតំបន់ណឹងប៉ុន្តែជ័យជំនះយើង៧៥ណឹង  គាត់ទៅរោងចក្រកែវ ។

សុជា៖  រោងចក្រកែវ?

លាង៖  ចាំ ។

សុជា៖  ចុះកាលណឹងគាត់មានប្រពន្ធរឺនៅ?

លាង៖  កាលណឹងគាត់ចូលរោងចក្របានប៉ុន្មានឆ្នាំទេ  បានមានប្រពន្ធមុនគេចាប់ ។

សុជា៖  គាត់ដែលមកលេងផ្ទះទេក្រោយ៧៥?

លាង៖  អត់ៗសោះ ។

សុជា៖  ពេលដែរចូលទៅភ្នំពេញហើយចូលទៅធ្វើការនៅរោងចក្រណឹងអត់ដែរមកទេ?

លាង៖  អត់ដែរមកសោះ ។

សុជា៖  អាណឹងរោងចក្រអីគេ  រោងចក្រកែវ?

លាង៖  ចាំ ។

សុជា៖  នៅឯណាទៅ?

លាង៖  នៅចំការដូង  ស្អីអូរបែកក្អមអីយ៉ាងម៉េចទេ ។

សុជា៖  អូរបែកក្អម?

លាង៖  ចាំ ។

សុជា៖  ឋានៈគាត់ជាស្អីគេ?

លាង៖  ឋានៈគាត់ពូជាប្រធានរោងចក្រណឹង ។

សុជា៖  ប្រធានរោងចក្រ?

លាង៖  ចាំ ។

សុជា៖  ចុះរាល់ថ្ងៃមាននៅសល់រូបថតគាត់ទេ?

លាង៖  រូបថតគាត់មាននៅផ្ទះបងនៅទួលក្រសាំង ។

សុជា៖  រូបថតគាត់  ថតតាំងពីអង្កាល់?

លាង៖  រូបថតគាត់ថតតាំងពីនៅរៀន ។

សុជាៈ ចុះមីងហេតុអីបានដឹងថាគាត់ធ្វើការនៅរោងចក្រកែវ បើគាត់មិនដែរមកលេងផង?

លាងៈ ខ្ញុំនៅកន្លែងភូមិអូរបែកខ្អមមក ហើយគាត់ឲ្យដំណឹងមកខ្ញុំទៅលេង ទៅលេងហើយបានខ្ញុំគេរើសចូលនៅពោធិ៍ចិនតុងណឹងបានបែកគ្នារហូតទល់តែនេះណឹងទៅ ។

សុជាៈ អីចឹងមីងធ្លាប់ទៅលេងគាត់នៅរោងចក្រកែវណឹង?

លាងៈ ចា៎ ។

សុជាៈ ទៅលេងបានប៉ុន្មានដងដែរ?

លាងៈ បានម៉ាដង ហើយគាត់អត់ស្គាល់ខ្ញុំទេ ហើយ ។

សុជាៈ ចុះកាលណឹងមីងទៅដល់ឋានៈគាត់ជាស្អីៗមីងអាចដឹងទេ?

លាងៈ ចាំមើលគេលាក់ខ្ញុំនេះទៅដល់ទៅសួរពេលក្នុងរោងចក្រគេអត់ប្រាប់ទេខ្ញុំថាគាត់បងខ្ញុំបង្កើត ហើយដល់ពេលនេះគេថាអោបងគាត់ប្រធានរោងចក្រគេលាក់គេអត់ប្រាប់ឈ្មោះ ទល់ដើរទៅដល់តែម្តងបានគេនេះណឹងគេប្រាប់ អាណឹងដូចដើរដល់អីចឹងទៅគេប្រាប់ណឹងអីចឹងទៅ ។

សុជាៈ បាទទៅលេងបានប៉ុន្មានថ្ងៃ?

លាងៈ ទៅលេងបានភ្លែតណឹង ហើយនៅអូរបែកខ្អមនៅមាត់រោងចក្រអាកន្លែងមាត់ទ្វាររោងចក្រណឹង ។

សុជាៈ កាលណឹងគាត់មានប្រពន្ធរឺពេលមីងទៅលេងគាត់ណឹង?

លាងៈ នៅ ។

សុជាៈ ចុះក្រោយមកទៀត?

លាងៈ ក្រោយមកទៀតខ្ញុំអត់បានទៅ ខ្ញុំចូលពោធិ៍ចិនតុងទៅ ។

សុជាៈ មីងចូលពោធិ៍ចិនតុងធ្វើអី?

លាងៈ គេរើសយកទៅបម្រើភ្ញៀវ ។

សុជាៈ ចុះមីងក្រោយមកទៀតមានបានទទួលដំណឹងពីគាត់ទេ?

លាងៈ អត់ ។

សុជាៈ ចុះថាគេចាប់គេអីនោះ?

លាង: ថាគេចាប់នោះអាណឹងបែកហើយណឹងខ្ញុំរត់មកផ្ទះហើយ បានអ្នកផ្ទះនិយាយប្រពន្ធគាត់ណឹងមកពីកោះធំមកនិយាយថាគេចាប់គាត់ ។

សុជា: គាត់ថាម៉េច?

លាង: គាត់ថាមានកូនហើយកូនណឹងមិនដឹងស្លាប់មិនដឹងរស់ អាណឹងប្រពន្ធនិយាយ ។

សុជា: ចុះពេលប្រពន្ធនិយាយណឹងកូនមកជាមួយប្រពន្ធណឹងដែរ រឺអត់?

លាង: ណឹងមកជាមួយតូចដែរហើយគាត់ថាមិនមែនកូនគាត់ទេ ប៉ុន្តែមុខដូចបងខ្ញុំប្រហែលជាកូនគាត់ហើយចេះតែស្មានទេណា ។

សុជា: ប្រពន្ធគាត់ឈ្មោះអីគេ?

លាង: ឈ្មោះឌី ហាង ។

សុជា: ស្រុកកំណើតនៅឯណា?

លាង: នៅកោះធំ ។

សុជា: គាត់ធ្វើអីដែរកាលជំនាន់ប៉ុល ពត?

លាង: គាត់នៅរោងចក្រតពានេះ ។

សុជា: រោងផ្សេង?

លាង: គាត់នៅរោងចក្រផ្សេងគ្នា ។

សុជា: ចុះប្រពន្ធណឹងគាត់ប្រាប់ថាគេចាប់ប្តីគាត់?

លាង: ចាំគេចាប់មុន ។

សុជា: គាត់មានប្រាប់ទៀតទេថាគេចាប់ដាក់ឯណា?

លាង: អត់ថាគេចាប់ទៅមុនបែក៣ថ្ងៃ មុនបែកយើង៧មករា ។

សុជា: កាលគេមកចាប់ណឹងគេចាប់គ្នាប៉ុន្មាននាក់?

លាង: មិនដឹងគ្នាប៉ុន្មាននាក់ គេចាប់ប្រធានៗ ។

សុជា: ហើយខ្ញុំសួរពីវិញ ពេលក្រោយ៧៩មកមានដែរបានទទួលដំណឹងពីបងមីងដែរ?

លាង: ប៉ុនពួសួរគេថាគាត់នៅរស់ៗ ។

សុជា: ថានៅឯណា?

លាង: ថានៅស៊ឹងត្រែង ប៉ុន្តែមិនដឹងគេថាស្មាន រឺគេថាយ៉ាងម៉េចមិនដឹងទេអត់សូវជឿដែរ ។

សុជាៈ ពូតាមពីណាគេ?

លាងៈ ពូសួរគេថាលាន់ៗណឹងណា អាណឹងពាក្យចចាមអារាម ។

សុជាៈ ពូដឹងណឹងយូរហើយរឺនៅ?

លាងៈ យូរហើយ ។

សុជាៈ ប្រហែលប៉ុន្មានឆ្នាំហើយ?

លាងៈ តាំងពី៧៩នោះណឹង ហើយបើគាត់នៅគាត់មកហើយ ។

សុជាៈ ចុះមីងផ្ទាល់ មីងចូលបដិវត្តន៍ឆ្នាំណា?

លាងៈ ៧៣ ។

សុជាៈ ចូលទៅមុនដំបូង ចូលទៅធ្វើអីគេ?

លាងៈ ចូលទៅមុនដំបូង ទៅវែកបាយ ។

សុជាៈ វែកបាយនៅឯណា?

លាងៈ វែកបាយចូលសមរភូមិដែរ វែកជញ្ជូនទៅត្រើយកើតនេះគេហៅម្តុំ កាលណឹងវៃម្តុំកោះអន្លង់ចិននេះ ។

សុជាៈ កោះក្របី?

លាងៈ អត់ទេគេវៃកន្លែងកោះអន្លង់ចិនណឹង ហើយខ្ញុំវែកបាយពីត្រើយខាងកើតមក ។

សុជាៈ ស្វាយរលំ?

លាងៈ មិនមែនស្វាយរលំទេទេត្រើយកើតនោះ ។

សុជាៈ ព្រែកថ្មី?

លាងៈ ព្រែកថ្មី ព្រែកទាហានសោណឹង ខ្ញុំនៅម្តុំណឹង ។

សុជាៈ នៅព្រែកដូង?

លាងៈ ចា៎ ព្រែកដូង ។

សុជាៈ ចុះទៅវែងបាយដល់អន្លក់ទៅបាន?

លាងៈ វែកបាយបានម៉ាឆ្នាំបានចុលសមរភូមិណឹងគេ ។

សុជាៈ ចូលវៃកាន់កាំភ្លើង?

លាងៈ កាន់កាំភ្លើង ។

សុជាៈ ភ័យទេ?

លាង៖ ភ័យរត់ទៅគ្រាប់ដូចជះអង្កាម ប៉ុន្តែអត់ត្រូវទេ ។

សុជាៈ ចុះមីងកាលណឹងចូលទៅនៅក្នុងកងពលណាដែរ?

លាង៖ កងពល១១ ។

សុជាៈ ប្រធានកងពលពីណាគេ?

លាង៖ តាសោម ។

សុជាៈ ចុះប្រធានវរៈ?

លាង៖ ប្រធានវរៈ អើចង់ភ្លេចឈ្មោះគាត់ហើយ ។

សុជាៈ វរៈលេខប៉ុន្មាន?

លាង៖ វរៈលេខ៣៥ ។

សុជាៈ ចុះប្រធានក្រុមមីងឈ្មោះអីដែរ?

លាង៖ ប្រធានក្រុមខ្ញុំភ្លេចហើយ ។

សុជាៈ ចុះវៃបានប៉ុន្មានសមរភូមិដែរ?

លាង៖ វៃកោះអន្លង់ចិនហើយ ទៅវៃនៅផ្លូវជាតិលេខ៣នោះទៀតម្ដុំភ្នំស្រង់នេះ ។

សុជាៈ ឈ្នះគេទេ?

លាង៖ ឈ្នះវៃសុទ្ធតែឈ្នះទាំងអស់ ។

សុជាៈ យើងវៃអីចឹងយុទ្ធជន យុទ្ធនារីវៃជាមួយគ្នាទេ?

លាង៖ វៃឡូកជាមួយគ្នា ហើយផ្លាស់ពីផ្លូវជាតិលេខ៣មក វៃផ្ដាច់ព្រាត់យើងសិត្បូនេះ ។

សុជាៈ ចូលតាខ្មៅ?

លាង៖ ចូលតាខ្មៅអាផ្ដាច់ព្រាត់ចូលតាខ្មៅ ។

សុជាៈ ដល់ពេលបានជ័យជំនះចូលទៅដល់ភ្នំពេញទៅនៅឯណា?

លាង៖ នៅកន្លែងក្រោយផ្ទះលន់ ណុល ។

សុជាៈ អាណឹងគេឲ្យធ្វើអីគេ?

លាង៖ នៅក្រោយផ្ទះលន់ ណុល អាណឹងដើរយាមតាមមុខសញ្ញាណឹងយើងយាមសម្ភារៈអាណឹង គេរើសម្ភារៈដាក់ឃ្លាំងទៅអាណឹងគេឲ្យយាមឃ្លាំងទៅ ហើយដល់ពេលនេះទៅគេរើសយកទៅពោធិ៍ចិនតុង ។

សុជា៖ ចុះពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមីងជួយជម្លៀសគេដែរ?

លាង៖ ជួយជម្លៀសដែរណឹង ។

សុជា៖ កាលណឹងជម្លៀសណឹងមានបញ្ហាពីត្រឹមណាមកដែរ?

លាង៖ បញ្ហាពីកងពល ប៉ុន្តែអត់មានធ្វើបាបអីទេ ។

សុជា៖ គេនិយាយថាយ៉ាងម៉េច?

លាង៖ គេថាឲ្យប្រជាជនចេញឲ្យអស់ទៅហើយគេបោសសម្អាតហើយគេយកប្រជាជនយកមកដាក់វិញណឹង ។

សុជា៖ តែអត់មានប៉ះពាល់អីដល់អាយុជីវិតប្រជាជនទេ?

លាង៖ អត់ទេ ។

សុជា៖ ហើយគេមានប្រាប់ថាមិនឲ្យប៉ះពាល់?

លាង៖ អត់ៗ ហើយខ្ញុំអាគេសម្លាប់មនុស្សណឹងអត់ដឹងទៀត អត់មានដឹងថាគេសម្លាប់ឯណាអត់ កន្លែងខ្ញុំគឺបិតជិតអត់ដឹង ។

សុជា៖ មីងគេយក មីងគេយកទៅផ្ទះលន់ ណុលហើយមកបានគេឲ្យទៅអូរបែកក្អម អូរបែកក្អមគេឲ្យធ្វើអីគេអាណឹង?

លាង៖ អាណឹងគេឲ្យនៅសម្រាកណឹង សម្រាកយកកម្លាំង ។

សុជា៖ អាណឹងផ្ទះលន់ ណុលណឹងបានប៉ុន្មានថ្ងៃ?

លាង៖ នៅយូរដែរម៉ាឆ្នាំ ។

សុជា៖ អាណឹងដើរប្រមូល ហើយយាម?

លាង៖ ដើរយាមហើយរើសសម្ភារៈណឹងដាក់ឃ្លាំងហើយបានគេផ្លាស់ឲ្យទៅអូរបែកក្អម ។

សុជា៖ កាលណឹងនៅក្នុងកងពលអីគេ កាលនៅផ្ទះលន់ ណុល?

លាង៖ អាណឹងនៅកងពល១១ ។

សុជា៖ ប្រធានពីណាគេ?

លាង៖ ប្រធានកងពលណឹងតាសោមណឹង?

សុជា៖ តាសោមដដែរ? .

លាង៖ ចាំ ។

សុជា៖ ហើយវរះ?

លាង៖ ហើយចុះពីណឹងទៀតអាណឹងប្រធានកងពល៥០២ ។

សុជា៖ ពីណាគេប្រធានកងពល៥០២?

លាង៖ តាម៉េត គាត់កាន់ខាងកងទ័ពអាកាសណាស់ ។

សុជា៖ ចុះយ៉ាងម៉េចបានមីងទៅស្គាល់កងពល៥០២វិញ?

លាង៖ អាណឹងគេចាប់តាសោមណឹងអស់ទៅ ពួកខ្ញុំអាប៉ាត់អាប៉ាយអត់មានកងពល អត់មានកង វរះអី តានេះគេចេះតែដើរដាក់ចូលទៅណា?

សុជា៖ សោមណឹងជីបានគេចាប់?

លាង៖ គេថាគាត់ក្បត់ ។

សុជា៖ គេចាប់ឆ្នាំណា?

លាង៖ គេចាប់នៅឆ្នាំ ៧៦, ៧៧អីវ៉ាន់ណឹង ។

សុជា៖ ហើយពេលគេចាប់គាត់ ក្រោយពីទៀតមានពីណាទៀតទេ?

លាង៖ មានច្រើនណាស់តែតាមកងពលអីចឹងទៅគេចាប់កងវរះមកដល់កងហាអីណឹងទៅ អាណឹង អស់មេណឹងទៅបានកូនណឹងអាប៉ាត់អាបាយដើរនៅកងពលគេ ។

សុជា៖ ចុះមីងទៅនៅកងពល៥០២ណឹងមីងនៅឯណា?

លាង៖ ខ្ញុំទៅនៅអូរបែកខ្អមហើយ ។

សុជា៖ ពីណាប្រធានក្រុម?

លាង៖ ប្រធានក្រុមឈ្មោះបងរ៉ន ។

សុជា៖ ស្រី រឺប្រុស?

លាង៖ ស្រី ។

សុជា៖ គេឲ្យធ្វើអីគេនៅណឹង?

លាង៖ អាណឹងនៅសម្រាកយកកម្លាំង ។

សុជាៈ អត់ធ្វើស្រែធ្វើអីទេ?

លាងៈ អត់ទេ ។

សុជាៈ ចុះប្រធានវរៈ?

លាងៈ ប្រធានកងវរៈគេទើបតែចាប់ត្រង់ណឹងដែរ នៅអូរបែកខ្អមណឹង ។

សុជាៈ គាត់ឈ្មោះអីគេ ។

លាងៈ ឈ្មោះស្រ៊ូ ។

សុជាៈ ស្រី រឺប្រុសនៅណឹង?

លាងៈ ភ្លេចហើយ នៅចាំតែកងពល ។

សុជាៈ ចុះដល់ពេលនៅសម្រាក់នៅអូរបែកខ្អមណឹងបានប៉ុន្មានថ្ងៃ?

លាងៈ បានពីរខែ ពីរខែគេរើសគេចម្រាញ់គេរើសអ្នកប្រវត្តិរូបល្អអាណឹងគេរើសមកពោធិ៍ចិនតុង ណាចាំ ។

សុជាៈ គេរើសមកគ្នាប៉ុន្មាននាក់គ្នាមីងណឹង?

លាងៈ គ្នា១០នាក់ ។

សុជាៈ ចុះអ្នកផ្សេងទៀត?

លាងៈ អ្នកផ្សេងទៅតាមខេត្តកំពង់ធំ កំពង់ឆ្នាំងសព្វ ។

សុជាៈ គេយកទៅអីចឹង?

លាងៈ ចាំគេឡូកគ្នា ។

សុជាៈ ហើយគេរើសអ្នកប្រវត្តិរូបល្អណឹងល្អយ៉ាងម៉េច?

លាងៈ អាណឹងមិនដឹងប្រវត្តិរូបយ៉ាងម៉េច អាណឹងដូចថាយើងអត់មានខុះខាតសីលធម៌យើងល្អអត់ មានប៉ះពាល់សម្ដីធំតូចអីទៅលើគេណឹង អាណឹងប្រវត្តិរូបល្អហើយ ។

សុជាៈ ចុះកាលណឹងគេចាប់បងមីងរឺនៅ?

លាងៈ នៅទេ ។

សុជាៈ ហើយចូលទៅនៅពោធិ៍ចិនតុងណឹងធ្វើអីគេ?

លាងៈ ចូលទៅនៅពោធិ៍ចិនតុងណឹងខ្ញុំបម្រើរភ្ញៀវ កាលណឹងសម្ដេចអីចុះមកណឹងសម្ដេចឪណឹង កាលណឹងគាត់នៅក្មេង ខ្ញុំវ៉ាន់កាន់ផ្កាមាំបាច់ពីរបាច់ណឹង ហើយស្លៀកពាក់ក៏ស្អាតដែរ ។

សុជាៈ  កាលណឹងគេឲ្យស្លៀក ពាក់អីគេ?

លាងៈ  ស្លៀកពាក់ហូរ ហើយពាក់អាវបា៉ក់ដៃត្រឹមនេះហើយគេចែកនាឡិការ ។

សុជាៈ  ចុះស្បែកជើង?

លាងៈ  ណឹងស្បែកជើងអីភ័ន់ សុទ្ធតែស្បែកជើងទទួលភ្ញៀវគេណឹង ។

សុជាៈ  មិនមែនស្បែកជើងកង់ឡានទេ?

លាងៈ  មិនមែនទេ ។

សុជាៈ  ចុះដល់ពេលភ្ញៀវក្រោយៗមកទៀតគេមានស្លៀកពាក់អីចឹងដែរទេ?

លាងៈ  ណឹងស្លៀកពាក់អីចឹង ។

សុជាៈ  មីងបានទទួលភ្ញៀវក្រៅពីសម្តេច កាលណឹងសម្តេចមកនៅឆ្នាំណា?

លាងៈ  សម្តេចមកឆ្នាំ៧៦ ។

សុជាៈ  កាលណឹងខែណា?

លាងៈ  ខែណាទេខ្ញុំអត់សួរចាំ ។

សុជាៈ  ចុងឆ្នាំ រឺដើម?

លាងៈ  ចុងឆ្នាំ ដល់ពេលសម្តេចយាងមកហើយអត់មានដឹងពីសម្តេចយា៉ងម៉េចទេអត់ដឹងសោះ ។

សុជាៈ  កាលណឹងសម្តេចយាងមកជាមួយពីណាគេ?

លាងៈ  សម្តេចយាងមកជាមួយកូនៗរបស់គាត់ណឹងមកប្រទេសយើង ។

សុជាៈ  ប៉ុន្មាននាក់?

លាងៈ  មិនដឹងប៉ុន្មាននាក់បើឡានច្រើនម៉ាយន្តហោះតែម្តង ។

សុជាៈ  ចុះមានសម្តេចម៉ែមកតាមទេ?

លាងៈ  សម្តេចម៉ែមកតាមកូនៗគាត់ណឹងមកទាំងអស់ ។

សុជាៈ  ចុះអ្នកដឹកនាំនៅភ្នំពេញពីណាទៅទទួល?

លាងៈ  អ្នកដឹកនាំនៅភ្នំពេញមានតែខៀវ សំផន ។

សុជាៈ  ហើយពីណាទៀត?

លាងៈ  មិនដឹងពីណាទៀតទេ ។

សុជាៈ  កាលណឹងហេតុអីបានមីងស្គាល់ខៀវ សំផន?

លាង៖ ខ្ញុំធ្លាប់បម្រើផ្ទះគាត់ណឹង គេយកទៅដាក់ផ្ទះអត់លេខ អាណឹងតាំងពីខ្ញុំអត់ទាន់ចូលពោធិ៍ចិនតុង ។

សុជា៖ ធ្លាប់ទៅបម្រើផ្ទះខៀវ សំផន?

លាង៖ ណឹងហើយបម្រើ ប៉ុន្តែមិនសូវមាត់មិនករអីទេ គាត់ទៅធ្វើការអីចឹងហើយមកវិញគ្រាន់តែបម្រើបោសម្អាតអី ។

សុជា៖ នៅបានប៉ុន្មានថ្ងៃនៅផ្ទះខៀវ សំផន?

លាង៖ នៅបានពីរបីថ្ងៃណឹង ។

សុជា៖ កាលណឹងមុនអាថ្ងៃគេរើសចូលទៅពោធិ៍ចិនតុង?

លាង៖ មុនគេរើសចូលពោធិ៍ចិតុង ។

សុជា៖ ចុះទៅទទួលណឹងខៀវ សំផនគាត់ជិះអីទៅ?

លាង៖ ជិះឡាន ។

សុជា៖ ទៅតែម្នាក់គាត់ទេ?

លាង៖ ទៅម្នាក់គាត់អីទៅគ្នាច្រើន ឡានឡើងដង្ហែរមាំគំនរ ។

សុជា៖ ស្គាល់តែខៀវ សំផនទេ ចុះអៀង សារី?

លាង៖ អត់ស្គាល់ទេ មិនដឹងមុខយ៉ាងម៉េចទេ ។

សុជា៖ ប៉ុល ពតអី?

លាង៖ ប៉ុល ពតក៏អត់ ។

សុជា៖ ចុះមានទទួលភ្ញៀវណាផ្សេងទៀតទេ ចុះក្រោយមកទៀត?

លាង៖ ក្រោយមកទៀតគេផ្លាស់ឲ្យទៅនៅពោធិ៍ចិនតុងទៅ ។

សុជា៖ នៅពោធិ៍ចិនតុងធ្វើអីគេ?

លាង៖ នៅពោធិ៍ចិនតុងក្រៅពីទទួលភ្ញៀវហើយនាំគ្នាបោសថ្នល់ហោះណឹងនាំគ្នាបោសចេញដើម្បីកុំឲ្យយន្តហោះបើកទៅគ្រឡាប់ ។

សុជា៖ គ្នាប៉ុន្មាននាក់នៅកន្លែងណឹង?

លាង៖ គ្នាជាង១០នាក់ ។

សុជា៖ ពីណាគេប្រធាននៅណឹង?

លាង៖ ឈ្មោះបងអេង ។

សុជា៖ គាត់អ្នកភូមិនៅស្រុកខាងណាដែរ?

លាង៖ គាត់នៅខេត្តតាកែវ ។

សុជា៖ ចុះប្រធានគ្រប់គ្រងធំនៅណឹងឈ្មោះអីគេ?

លាង៖ ណឹងឈ្មោះតាម៉េតណឹង គាត់ប្រធានកងពល៩០២ណឹងហើយបន្ទាប់មកកងវរៈ ។

សុជា៖ ឈ្មោះអីគេ?

លាង៖ ឈ្មោះឆាយ ឈ្មោះគឿន ។

សុជា៖ តាម៉េតណឹងមានដឹងទេ ស្រុកគាត់នៅឯណា?

លាង៖ គាត់នៅកំពត ។

សុជា៖ ចុះតាឆាយនោះ?

លាង៖ តាឆាយនោះនៅកំពង់ឆ្នាំង ។

សុជា៖ ចុះតាគឿន?

លាង៖ តាគឿននៅព្រែកអំបិល ។

សុជា៖ គាត់នៅរស់ដែរ?

លាង៖ មិនដឹងនៅរស់ ប៉ុន្តែតាំងបែកមកសួរសុខទុក្ខគ្នាថាយ៉ាងម៉េចគ្នាយើងមានស្លាប់មានរស់អត់ ខ្ញុំថានៅរស់ទាំងអស់ ។

សុជា៖ មីងធ្វើការនៅពោធិ៍តុងណឹងការងារវាលំបាកដែរ?

លាង៖ ការងារធម្មតា ។

សុជា៖ ធម្មតា?

លាង៖ ចា៎ ។

សុជា៖ ចុះការហូបចុកអី?

លាង៖ ហូបចុកវាអត់បញ្ហាទេ ។

សុជា៖ ចុះមានដែរភ្ញៀវបរទេសមកទេ?

លាង៖ ភ្ញៀវបរទេសមក ភ្ញៀវចិន ចិនមកញឹកជាងគេ ។

សុជា៖ មីងមានស្គាល់ឈ្មោះគេទេ?

លាង៖  អត់ ។

សុជា៖  ចុះដល់ពេលគេមកមីងធ្វើយ៉ាងម៉េច?

លាង៖  អាណឹងយើងកាន់តែផ្កាណឹងយកទៅទទួលគេ ជូនគេ ជូនដំណើរគេហើយ ។

សុជា៖  កាលសម្តេចមក ភ្ញៀវចិនមកអីមានទ័ពគេទៅហែរហមទេ?

លាង៖  ណឹងមាន ។

សុជា៖  ចុះកាលសម្តេចមកមនុស្សទៅទទួលច្រើនទេ?

លាង៖  មនុស្សច្រើនឡើងពេញមិនកងពលណាៗទៅទាំងអស់  ប៉ុន្តែសុទ្ធតែស្លៀកពាក់ស៊ីវិលយើង ធម្មតាមិនស្លៀកពាក់ទាហាន ប៉ុន្តែសុទ្ធតែកងទ័ពទេណា ។

សុជា៖  មិនមែនស្លៀកពាក់អាវខ្មៅ?

លាង៖  ចា៎ អត់ទេ ។

សុជា៖  ចុះប្រជាជនធម្មតាមានបានទៅទទួល?

លាង៖  អត់ទេប្រជាជន តែសុទ្ធកងទ័ព ។

សុជា៖  ចុះទៅទទួលភ្ញៀវចិនភ្ញៀវបរទេសអីមានអ្នកទៅទទួលច្រើនទេ?

លាង៖  អាណឹងអត់ទេទៅទទួលពីរបីនាក់ទេ ទៅទទួលសម្តេចបានមានមនុស្សច្រើន ។

សុជា៖  តែក្រោយមកមីងថាអត់ដែរបានទទួលដំណឹងពីសម្តេច?

លាង៖  ចា៎ អត់បើថាប៉ុល ពត, អៀង សារីអីខ្ញុំអត់ស្គាល់ ខ្ញុំស្គាល់តែខៀវ សំផន ។

សុជា៖  កាលណឹងផ្ទះគាត់នៅឯណា?

លាង៖  នៅជិតផ្សារអូរឡាំពិក ។

សុជា៖  នៅជិតស្តាត?

លាង៖  ចា៎  កាលណឹងគាត់រៀនដូចថានយោបាយ  កាលណឹងរៀនទូទាំងប្រទេស  តាំងពីក្រសួងការបរទេសសព្វមុខ ។

សុជា៖  មីងចូលរៀនដែរ?

លាង៖  ខ្ញុំបម្រើរភ្ញៀវណឹង ។

សុជា៖  គ្នាច្រើនទេ?

លាង៖  គ្នាច្រើន ។

សុជា៖ រៀននៅស្តាតណឹង?

លាង៖ ចា៎ ។

សុជា៖ នៅឆ្នាំណា?

លាង៖ នៅឆ្នាំ៧៥ ។

សុជា៖ ដែរបែកហើយណឹង,

លាង៖ បែកហើយប្រហែលពីរខែ ។

សុជា៖ ទ័ពមកគ្រប់ពីតំបន់?

លាង៖ មកគ្រប់ទូទាំងប្រទេស តាំងពីក្រសួងការបរទេស ក្រសួងកសិកម្ម មករៀនទាំងអស់ ។

សុជា៖ គេរៀនពីស្អីគេខ្លះ?

លាង៖ មិនដឹងរៀនពីស្អីខ្ញុំគ្រាន់តែបម្រើរភ្ញៀវ ទៅបោសណឹង ពេលទៅបត់ខោអាវឲ្យគេអ៊ីចឹងទៅណា គេទៅធ្វើការអ៊ីចឹងទៅបោសជូតសម្អាតផ្ទះអាណឹងយើងនៅខាងបម្រើរភ្ញៀវ ។

សុជា៖ កាលណឹងគេមកនៅណឹងគេស្នាក់កន្លែងណា?

លាង៖ គេស្នាក់នៅតាមអគារផ្ទះជិតណឹង ផ្ទះថ្មពីរជាន់ បីជាន់ណឹងអាជិតស្តាតណឹង ។

សុជា៖ គេរៀន បង្រៀនប៉ុន្មានថ្ងៃ?

លាង៖ បង្រៀនជួនណាមួយខែ ជួនកន្លះខែ ។

សុជា៖ កាលណឹងគេមកញឹក?

លាង៖ ជួនណាគេរៀនអស់អ៊ីចឹងទៅមេគេមករៀនមុនគ្រប់ក្រសួងគ្រប់មន្ទីរ ដល់ក្រោយមកអាបន្ទាប់ណឹងមករៀនទៀតតៗគ្នា ។

សុជា៖ កាលណឹងមីងខស្សព្រាហ៍ទៅទទួល ទៅបម្រើរគេណឹង?

លាង៖ ទៅទទួលភ្ញៀវ ។

សុជា៖ អាណឹងពេលដែលមិនទាន់ទៅធ្វើការនៅពោធិ៍ចិនតុងទេ?

លាង៖ ចា៎មិនទាន់ ។

សុជា៖ ចុះពេលទៅធ្វើនៅពោធិ៍ចិនតុងណឹងធ្វើតែនៅក្នុងពោធិ៍ចិនតុងណឹង អត់មានទៅធ្វើនៅឯណាក្រៅទៀតទេ?

លាង: អាណឹងធ្វើតែក្នុងពោធិ៍ចិនតុង គេអត់ឲ្យចេញទេ បើថា គេសម្លាប់មនុស្ស យ៉ាងម៉េចៗ ខ្ញុំអត់ ដឹងសោះទាល់តែពេលរត់ទៅបាត់ដំបងបានដឹងឮសួរគេនិយាយ បានដឹងគេសម្លាប់ មនុស្ស អត់ៗដឹង ។

សុជា: នៅពោធិ៍ចិនតុងណឹង កាលណឹងមានយន្តហោះចុះញឹកញាប់ទេ?

លាង: យន្តហោះចុះរាល់ថ្ងៃ ។

សុជា: ហើយច្រើនជាស្អីទៅ អ្នកមកណឹង?

លាង: អ្នកមកណឹងច្រើនតែចិន ហើយណឹងវៀត ណាមយូរម្តងៗ ។

សុជា: ចុះមានខាងពួកខាងប្រមុះស្រួចពីអឺរ៉ុបអីមកទេ?

លាង: អត់ អាណឹងឮសួរគេថ្នាក់ដឹកនាំគេថាភ្នំពេញណឹងមិនទាន់សម្អាតបានគេមិនទាន់ឲ្យមកទេ ។

សុជា: ហើយយូរហើយ?

លាង: យូរហើយ ។

សុជា: គ្រាន់តែនិយាយថាការដែលសម្អាតមិនទាន់បានណឹងប្រើពេលហើយមិនទាន់ឲ្យមក?

លាង: ណឹងអាណឹងជិតបែកហើយនៅក៏គេនិយាយថាកុំអាលមកណឹង ចាំគេសម្អាតណឹងអាណឹង គេអ្នកដឹកនាំណឹងគេនិយាយអីចឹង ។

សុជា: ចុះមានដែរគេបង្រៀននយោបាយ នយោអីមីងដែរ?

លាង: គេបង្រៀន ។

សុជា: ពីណាគេបង្រៀន?

លាង: គណៈវរៈ ។

សុជា: តាម៉េតណឹង?

លាង: ចា៎ ថ្នាក់វរៈ ថ្នាក់កងពល ថ្នាក់វរៈអីណឹង ។

សុជា: គេបង្រៀនពីស្អីខ្លះ?

លាង: គេបង្រៀនពីនយោបាយជំនាន់ណឹង ។

សុជា: បង្រៀនគេថាយ៉ាងម៉េចខ្លះ?

លាង: គេថាយើងតស៊ូរំដោះជាតិណឹងដើម្បីរំដោះម៉ែឪយើងស្អីៗសព្វគ្រប់ ខ្ញុំភ្លេចអស់ហើយ ។

សុជា: ចុះមានដែរគេលេងសិល្បៈអីឲ្យមើលដែរ?

លាង៖ អត់ដែរមានសិល្ប៍ទេមានតែគុន គុនចិនណឹង ។

សុជា៖ គេលេងរឿងអីគេទៅ?

លាង៖ គេលេងរឿងគេអ្នកតស៊ូអីគេទេ?

សុជា៖ ម៉ៅសេទុង?

លាង៖ ណឹងហើយ ម៉ៅសេទុងហើយស្អីណឹងសុទ្ធតែតស៊ូតែម្នាក់ឯងក៏អាចឈ្នះដែរ ។

សុជា៖ ហើយក្រៅពីនៅណឹងគេមានឲ្យមករៀននយោបាយនៅស្តាតអីទេ?

លាង៖ អត់ អត់សោះ អត់ដែរឲ្យចេញទៅក្រៅ ។

សុជា៖ ចុះមានដែរអ្នកធំអ្នកអីគេដើរពិនិត្យមើលកន្លែងធ្វើការនៅពោធិ៍ចិនតុងទេ?

លាង៖ អាណឹងដូចគេប្រគល់ផ្តាច់ម៉ាកងពល៥០២ឲ្យអាណឹងគេឲ្យត្រួតពិនិត្យតែម៉ាកងពលណឹងទេ ដូចអ្នកផ្សេងអត់មានទៅ ដូចមានការអីពីក្រៅទៅគេអ្នកធំណឹង... ។

សុជា៖ ចុះមីងកាលណឹងមានដែរមកលេងផ្ទះទេ?

លាង៖ អត់ទេ ។

សុជា៖ ចុះមានដែរសុំគេមកទេ?

លាង៖ សុំគេដែរគេអត់ឲ្យមក គេថាតែទៅនាំមាន ដូចថាគេធ្វើបាបម៉ែឪនៅឯនេះដឹង ។

សុជា៖ ហើយចុះគេនិយាយថាម៉េច គេនិយាយថាម៉ែនៅខាងក្រោយនេះ?

លាង៖ ខាងក្រោយនេះសុខសប្បាយទេ ។

សុជា៖ ចុះមីងមានដែរបានដឹងណឹងពីអ្នកផ្ទះនេះទៅទេ?

លាង៖ អត់មាន ។

សុជា៖ មិញមីងនិយាយថាបងមីងពីរបីនាក់ទៅបដិវត្ត?

លាង៖ ប៉ុន្តែនេះគាត់មកផ្ទះវិញ គាត់ធ្វើពេទ្យនៅទីនេះ ។

សុជា៖ បងស្រីមួយទៀតណឹង?

លាង៖ ចា៎ ។

សុជា៖ ឈ្មោះអីគេ?

លាង៖ ឈ្មោះឡុង ។

សុជា៖ គាត់មកធ្វើពេទ្យនៅភូមិនេះវិញកាលជំនាន់ប៉ុល ពត?

លាង៖ ចាំ ។

សុជា៖ អីចឹងនៅភ្នំពេញតែពីរនាក់មីងហើយណឹងបងប្រុស?

លាង៖ ណឹងនៅតែពីរនាក់បងប្រុស ។

សុជា៖ ក្រោយមកទៀតក៏អត់ដែរបានជួបបង?

លាង៖ អត់ដែរបានជួបគ្នាសោះខ្ញុំសុំគេទៅលេងបងគេអត់ ឲ្យទៅបងសុំមកលេងខ្ញុំក៏គេមិនឲ្យចូល ណឹងដូចថាខាងរោងចក្រកែវទៅរៀនកន្លែងខ្ញុំខាងក្រុមម៉េ ខាងអីចឹងណឹងគេនិយាយប្រាប់មក ខ្ញុំនេះថាសុំគាត់ទៅលេងគេអត់ឲ្យទៅ គេឯណោះក៏គេអត់ឲ្យមក ។

សុជា៖ កន្លែងមីងធ្វើការនៅពោធិ៍ចិនតុងចំពោះក្រុមមីងណឹងគ្រប់អីគេ ក្រុមទទួលភ្ញៀវ?

លាង៖ ក្រុមទទួលភ្ញៀវ ។

សុជា៖ គេមានបង្រៀវមានអីពីរបៀបរបបទទួលភ្ញៀវ?

លាង៖ អត់ទេ គេគ្រាន់តែពេលយន្តហោះជិតចុះហើយគេថាស្អែកយន្តហោះចុះហើយគេឲ្យយើងរៀបខ្លួនណឹងចាំទទួល ។

សុជា៖ កាលជំនាន់ណឹងមីងដែរថតរូប ដែរធ្វើប្រវត្តិរូបទេ?

លាង៖ ដែរធ្វើដែរកាលណឹងតែក្រោយមកមិនគេយកទៅណាទៅណីអស់ទៅ គេធ្វើញឹកញាប់មាំខែធ្វើម្តង ។

សុជា៖ គេសួរពីស្អីខ្លះ?

លាង៖ គេសួរពីនៅផ្ទះណឹងអីយាំងម៉េចធ្វើអីៗ ។

សុជា៖ អត់ទេកាលពីជំនាន់ប៉ុល ពត?

លាង៖ ចាំ ។

សុជា៖ ខាងណាគេមកធ្វើ?

លាង៖ ប្រធានក្រុម ។

សុជា៖ គេធ្វើ?

លាង៖ គេធ្វើហើយគេរាយការណ៍ទៅកងពល ។

សុជា៖ ចុះរាល់ថ្ងៃមីងមានសល់រូបថតអីទេ?

លាង៖ អត់បើរូបថតឥឡូវមាន ។

សុជាៈ  ចុះរូបថតពីមុន?

លាងៈ  រូបថតពីមុនអត់ដែរថត ។

សុជាៈ  ហឺគេអត់ឲ្យថត  រឺក៏យ៉ាងម៉េច?

លាងៈ  គេថតដែរតែថតកាន់កាំភ្លើងកាន់អី  ប៉ុន្តែរូបថតណឹងមិនដឹងទេយកទៅណាអស់ហើយ ។

**Side B**

សុជាៈ  ទៅដល់ថៃ?

លាងៈ  ចា៎ ។

សុជាៈ  រត់ចេញពីណាទៅ?

លាងៈ  រត់តាមផ្លូវបាត់ដំបង ។

សុជាៈ  រត់ចេញពីពោធិ៍ចិនតុងណឹងទៅ?

លាងៈ  ចា៎ ។

សុជាៈ  ចុះកាលនៅពោធិ៍ចិនតុងមឹងមានដែរបាត់មនុស្សបាត់អីទេ?

លាងៈ  ម៉ាក្រុមខ្ញុំណឹងទៅទាំងអស់គ្នា ។

សុជាៈ  ទៅដល់ណា?

លាងៈ  ទៅអឺចឹងទៅដល់បាត់ដំបងធ្លាក់ទៅប៉ោយប៉ែត     ធ្លាក់ដល់ប៉ោយប៉ែតអឺចឹងគេថាទៅឡើង តាមណឹងអត់រួចទេមកអឺចឹងមកប៉ៃលិនវិញ  ប៉ៃលិនមកអឺចឹងទៅថៃ  ចូលថៃបានម៉ាអាទិត្យ គេថានៅណឹងហើយខ្ញុំថាអត់នៅទេទៅផ្ទះវិញខ្ញុំនឹកម៉ែណាស់   ចុះតាំងចេញទៅឆ្នាំ៧១ណឹង រហូតអត់ដែរមកលេងម៉ែសោះ ។

សុជាៈ  មឹងមកដល់ផ្ទះឆ្នាំណា?

លាងៈ  មកតាំង៧៩ ។

សុជាៈ  ខែណាស្មានបានទេ?

លាងៈ  មើលខែស្ទូងស្រូវ ។

សុជាៈ  ដើមឆ្នាំ?

លាន: ដើមឆ្នាំ ។

សុជា: ប្រហែលខែ៥,៦ណឹង?

លាន: ណឹង ។

សុជា: មីងមកប៉ុន្មាននាក់?

លាន: មកម្នាក់ឯង ។

សុជា: កាលណឹងមកចូលតាម?

លាន: កាលណឹងចាំមើលខ្ញុំចុះពីនេះមកវិញដល់ពោធិ៍សាត់ណឹងបានឡើងទៅភ្នំម៉ាសាទៀតបានអត់បាយហូប ។

សុជា: ឡើងទៅភ្នំណឹងបានចុះមកវិញចាំខេត្តណា ពេលចូលសារភាព?

លាន: ខេត្តពោធិ៍សាត់ណឹង ។

សុជា: ខេត្តពោធិ៍សាត់វិញទៀត?

លាន: ចា៎ ដល់ទៅៗអីចឹងដល់បាត់ដំបងទៅចូលទៅថៃហើយដល់មកវិញមកតាមបរិល ។

សុជា: ចូលតាមបរិល?

លាន: ចា៎មកពោធិ៍សាត់ ។

សុជា: ពេលដែរចូលមកគេថាយ៉ាងម៉េច ពេលដែលចូលមកណឹងគេទទួលយើងណឹងគេនិយាយថាយ៉ាងម៉េច?

លាន: គេថា ឲ្យមកនៅពោធិ៍សាត់ណឹងសិនចាំមេគេមកបានអាណឹងគេដោះស្រាយទៀត ហើយដល់ពេលចាំមេណឹងមកអត់ឃើញដល់នេះគេថា តាំងយើងនាំគ្នារត់ឡើងភ្នំក្រវាញម៉ាសាទៀតអីចឹង ។

សុជា: ចុះមកផ្ទះនេះបានជិះអីមក?

លាន: បានដើរមករហូត ។

សុជា: ដើរម្នាក់ឯង?

លាន: ដើរគ្នាម៉ាគ្នាពួកខ្ញុំណឹង១០នាក់ ប៉ុន្តែមកអីចឹងគេចូលតាមផ្ទះគេទៅនៅកំពង់ឆ្នាំង កំពង់ធំតាមខេត្តគ្រប់ខេត្តខ្ញុំតែខេត្តកណ្តាល តែខ្ញុំម្នាក់ណឹង ។

សុជា: គ្នាមីង១០នាក់សុទ្ធតែអ្នកធ្វើការពោធិ៍ចិនតុង ?

លាង៖ ចាំ ។

សុជា៖ ឈ្មោះអីគេខ្លះ?

លាង៖ ច្រើនណាស់ ។

សុជា៖ នៅចាំខ្លះទេ?

លាង៖ ឈ្មោះបងពៅ ឈ្មោះបង ។

សុជា៖ បងពៅណឹងនៅឯណា?

លាង៖ បងពៅនៅខេត្តកំពង់ស្ពឺ ។

សុជា៖ ពីណាទៀត?

លាង៖ នៅកំពង់ឆ្នាំងឈ្មោះបងអីទេណេន ហើយបងហេងនោះនៅកំពតហើយនឿននោះនៅកំពត ។

សុជា៖ ចុះថានៅកំពង់ធំនោះ?

លាង៖ កំពង់ធំនោះបងអីទេ ភ្លេចអស់ហើយយូរដែរហើយ ។

សុជា៖ ចុះមកដល់ផ្ទះដំបូងសប្បាយចិត្តទេ?

លាង៖ មកដល់ចាញ់ចង់ងាប់ ។

សុជា៖ មកដល់ចាញ់ផ្ទះវិញ?

លាង៖ មកដល់ចាញ់តែឪណឹងបីខ្ទូតទឹកខ្ទូតអី ហើយបងខ្ញុំម្នាក់នោះមកដល់ស្លាប់ ។

សុជា៖ បងណា?

លាង៖ បងជីដូនមួយគាត់ទៅមុនខ្ញុំ ។

សុជា៖ កាលមីងធ្វើការនៅពោធិ៍ចិនតុងឋានៈមីងជាស្អីគេ?

លាង៖ អត់មានឋានៈអីផងកាលណឹង ។

សុជា៖ ចុះដល់ពេល មីងរៀបការនៅឆ្នាំណាដែរ?

លាង៖ រៀបការនៅឆ្នាំបែកហើយ ។

សុជា៖ កាលមុនរៀបការមីងមានបាននិយាយប្រាប់អ្នកជិតខាង រឺគ្រួសារមីងថាមីងទៅធ្វើការអីៗ និយាយប្រាប់ទេ?

លាង៖ និយាយប្រាប់ដែរ តែប្ដីខ្ញុំប្រច័ណ្ឌកាលណឹងវៃខ្ញុំ ។

សុជា៖ ប្រច័ណ្ឌថាយ៉ាងម៉េច?

លាង៖ ប្រច័ណ្ឌថាខ្ញុំនេះជិតាវអីចឹងធ្លាប់ធ្វើជិតាវ ហើយខ្ញុំស្រែក៏ចេះអីក៏ចេះហើយដល់ពេលមានប្ដី ប្ដីប្រច័ណ្ឌគ្រាន់តែនិយាយស្រីៗដូចគ្នាណឹងក៏អត់បានដែរ ។

សុជា៖ មីងរាល់ថ្ងៃនៅកូនប៉ុន្មានពីរនាក់?

លាង៖ ចាំ ។

សុជា៖ ប្រុសៗទាំងពីរអ្នក?

លាង៖ កូនពីរនាក់ អាមួយធំ ។

សុជា៖ អាយុប៉ុន្មានបង?

លាង៖ អាយុប្រាំមួយប្រាំពីរដប់ ។

សុជា៖ ពីមុនមកមានគេមកសួរនាំពីរឿងរ៉ាវរបស់មីងរបស់បងមីងអីចឹងទេ?

លាង៖ អត់ទេ ។

សុជា៖ ចុះពេលមានគេមកសួរនាំអីចឹងមីងមានអារម្មណ៍យ៉ាងម៉េចដែរ?

លាង៖ គេមកសួរពីបងខ្ញុំណឹងខ្ញុំនេះអរណាស់ថាបងខ្ញុំនៅរស់ហើយខ្ញុំខំបងសៀបណឹងប្រាប់ថា គេរកបងដែងអីចឹងខ្ញុំថាបងខ្ញុំនៅរស់ហើយខ្ញុំខំតែអរ ។

សុជា៖ ចុះពេលដែរខ្ញុំគ្រាន់តែថាខ្ញុំបានដំណឹងថាខ្ញុំមានតែប្រវត្តិរូបបងមីងអីចឹងដែរតែខ្ញុំមិនបានដឹងថាស្លាប់រឺរស់តើមីងយល់ថាមកដល់រាល់ថ្ងៃនេះគាត់ស្លាប់រឺរស់?

លាង៖ មិនដឹងស្លាប់ រឺរស់ខ្ញុំអត់ដឹងគាត់ស្លាប់ រឺរស់ផង ។

សុជា៖ រាល់ថ្ងៃប្រពន្ធគាត់ដែរមកលេង?

លាង៖ អត់ ។

សុជា៖ មីងធ្លាប់និយាយរឿងរ៉ាវណឹងប្រាប់កូនៗទេ?

លាង៖ ខ្ញុំនិយាយប្រាប់អីចឹងដែរ ។

សុជា៖ មីងគិតថារឿងរ៉ាវកាលពីជំនាន់ខ្មែរក្រហមណឹង គួរតែនិយាយប្រាប់ក្មេងៗបន្តទៀត រឺគួរតែបំភ្លេចចោល?

លាង៖ ខ្ញុំកាលណឹងខ្ញុំចេះតែថាជំនាន់តស៊ូអត់ប្រយោជន៍ទេខ្ញុំថាអីចឹងចុះបងខ្ញុំវ៉ាន់បាត់ឈឹង អីចឹងទៅដល់ពេលមកផ្ទះឈឺចាញ់ចង់ងាប់ចង់រស់អត់មានពីណាគិតគូរ ខ្ញុំថាតស៊ូជំនាន់ណឹងអត់ប្រយោជន៍ខ្ញុំថាអីចឹង ។

សុជាៈ ចុះកាលតស៊ូរបស់មីងពីមុនមិនដែរមានគេមកសួរ ចុះមានខ្ញុំមកសួរអីចឹងមីងយល់ថាយ៉ាង ម៉េចវិញការសួរនាំរបស់ខ្ញុំ?

លាងៈ ខ្ញុំភ័យវិញ ។

សុជាៈ ចុះមីងមុនដំបូងមីងថាការសួរនាំអត់មានពីណាមកសួរនាំអត់ប្រយោជន៍ ចុះឥឡូវបានខ្ញុំមក សួរ?

លាងៈ អត់ទេនិយាយតាំងពីមុនណឹងទាល់តែពេលឈឺអីវ៉ាន់ ទៅជាអន្តត់អីចឹងចំណាញ់តែអន្តត់ អត់ប្រយោជន៍អីចឹងអាណឹងខ្ញុំយល់ថាអីចឹង ។

សុជាៈ តែចំពោះខ្ញុំមកលើកនេះទោះបីមិនបានផ្តល់ប្រយោជន៍អីដល់មីងក៏ដោយ ក៏ប៉ុន្តែមីងបានរួម ចំណែកម៉ាចំណែកដែរ ក្នុងការកសាងប្រវត្តិសាស្ត្រនៅក្នុងសម័យខ្មែរក្រហមអីចឹងមីង ហើយមីងយល់យ៉ាងម៉េចពីការរស់នៅក្នុងរបបខ្មែរក្រហម ថារបបណឹងយ៉ាងម៉េចដែរ?

លាងៈ អីចឹងបានខ្ញុំថារបបខ្មែរក្រហមខ្ញុំអត់ដឹងថាគេធ្វើបាបយ៉ាងម៉េចខ្ញុំអត់ដឹង ទាល់តែពេលរត់ ទៅហើយបានខ្ញុំដឹងថាគេសម្លាប់ហើយគេធ្វើបាបប្រជាជន ។

សុជាៈ មីងយល់ថាការគ្រប់គ្រងនៅក្នុងសម័យខ្មែរក្រហមណឹងល្អរឺក៏អាក្រក់?

លាងៈ ខ្ញុំថាល្អទាស់តែសម្លាប់មនុស្ស ។

សុជាៈ ល្អត្រង់ណា?

លាងៈ ព្រោះអីល្អតាំងពីសីលធម៌ដូចដើរ ខ្ញុំវ៉ាន់នៅពោធិ៍ចិនតុងតែគេផ្លាស់ទៅនៅគ្រប់ខេត្តដូចជា កំពង់សោមទៅបាត់ដំបង ។

សុជាៈ ហេតុចុះយ៉ាងម៉េចបានជាគេផ្លាស់មីងទៅណឹង?

លាងៈ អាណឹងគេផ្លាស់ឲ្យទៅ ដូចន្ធុកពួកខ្ញុំបីនាក់ហើយក្រៅពីណឹងយុទ្ធជនហើយទៅវាអត់មានខូច សីលធម៌អីណឹងយុទ្ធជន ។

សុជាៈ ចុះមីងទៅតាមខេត្តទៀតកាលមីង?

លាងៈ ចា៎ ។

សុជាៈ ទៅយ៉ាងម៉េច?

លាងៈ ទៅទទួលភ្ញៀវតាមខេត្តទៀត ។

សុជាៈ ជិះអីទៅ?

លាន៖ ជិះឡាន ។

សុជា៖ ជិះឡានទៅ?

លាន៖ ចាំ ។

សុជា៖ ឧទាហរណ៍ភ្ញៀវគេទៅកំពង់សោម គេជិះអីទៅ?

លាន៖ គេជិះយន្តហោះ ។

សុជា៖ ហើយយើងចាំទទួលគេនៅកំពង់សោមទៀត?

លាន៖ ណឹងហើយ ។

សុជា៖ ពេលគេទៅសៀម រាប?

លាន៖ ទៅសៀម រាបជិះឡានទៅ ទៅចាំទទួលគេនៅឯនោះទៀត ។

សុជា៖ ញឹកញាប់ទេ?

លាន៖ ញឹកញាប់ដែរណឹង ។

សុជា៖ ទៅខេត្តណាខ្លះ?

លាន៖ ខេត្តកំពង់សោម សៀម រាប ហើយណឹងស្ទឹងត្រែង ។

សុជា៖ ចុះទៅស្ទឹងត្រែងជិះឡានទៅដែរ?

លាន៖ ជិះឡានទៅដែរណឹង ។

សុជា៖ ជិះមិនយូរថ្ងៃហើយ?

លាន៖ ពីរថ្ងៃ ។

សុជា៖ ទៅទទួលភ្ញៀវ ភ្ញៀវអីគេ?

លាន៖ ភ្ញៀវខ្មែរយើងណឹងពេលគេទៅការទៅធ្វើការនៅណឹង?

សុជា៖ ឈ្មោះអីគេមឹងមានដែរចាំឈ្មោះគេទេ?

លាន៖ អត់ទេ ។

សុជា៖ ហើយរាល់ថ្ងៃមឹងមានដែរដឹងពីរឿងរ៉ាវដែរទាក់ទងពីរឿងមេដឹកនាំខ្មែរក្រហមទេ អត់ដែរទេ
រឿងតុលាការរឿងអីមឹងដែរ?

លាន៖ ខ្ញុំមានរ៉េយោណាស្តាប់ ។

សុជា៖ មឹងមានទូរទស្សន៍ដែរ?

លាង៖ ទូរទស្សន៍មានដែរប៉ុន្តែអត់អាគុយយូរដែរម៉ាឆ្នាំហើយមានតែទូរទស្សន៍ ហើយខូចអាគុយខ្ញុំរកលុយទិញអត់បាន ។

សុជា៖ ចុះមីងបង មីងគិតថាគេចាប់អីចឹងគេយកសម្លាប់ ហើយបើរាល់ថ្ងៃមីងដឹងអ្នកដែរសម្លាប់បងមីងរស់នៅជិតខាងមីង មីងមានអារម្មណ៍ចង់សងសឹងគេដែរទេ?

លាង៖ ចង់សងសឹកដែរ ប៉ុន្តែគេថាកុំយកគំរ៉ាប់តាម អាណឹងតាមខ្ញុំយល់ខ្ញុំអត់សម្លាប់គេអាណឹងទុកដូចជាអាសាបង់ចុះ ។

សុជា៖ ចុះបើអ្នកដែលដល់ណឹងគេមានកូនចៅទៅរៀន ជាមួយកូនចៅមីងតើមីងគិតថាឃាត់ឃាំងមិនឲ្យកូនចៅមីងមិនឲ្យលេងជាមួយកូនគេទេ?

លាង៖ កូនគេអ្នកដែលដល់ខ្ញុំឃាត់ ខ្ញុំឃាត់កូនខ្ញុំ ខ្ញុំខ្លាចអីចេដូចទៅមានធុងបាសធុងអីទៅកូនគេអ្នកមានរឿងគេវៃដល់កូនយើង អាណឹងខ្ញុំឃាត់កូនអត់ឲ្យទៅលេងទេ ។

សុជា៖ តែទៅរៀនទៅសូត្រអីនិយាយជាមួយគ្នាធម្មតាទេ?

លាង៖ អាណឹងអត់អីទេ ។

សុជា៖ រាល់ថ្ងៃណឹងគេបម្រុងបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមមីង មីងយល់យ៉ាងម៉េចដែរ?

លាង៖ បង្កើតៗទៅ ។

សុជា៖ មីងគិតថាគួរឲ្យមានដែរ រឺក៏អត់?

លាង៖ ណឹងគួរឲ្យមានដែរ ។

សុជា៖ ហេតុអីបានជាមីងថាគួរឲ្យមាន?

លាង៖ អាណឹងយើងគំនិតចង់ឲ្យមានទៅវាត្រឹមត្រូវ កាត់ទោសយ៉ាងម៉េចតាមតុលាការវិនិច្ឆ័យទោសអាណឹងយើងធ្វើខុសយើងទទួលខុសទៅ យើងធ្វើត្រូវតាមត្រូវមក ។

សុជា៖ មីងគិតថាគួរតែកាត់ទោសមេដឹកនាំខ្មែរក្រហមតាមកម្រិតណាដែរ?

លាង៖ ដឹងអីខ្ញុំមិនសូវដឹងដែរ ស្រេចតែតុលាការកាត់ទៅ ។

សុជា៖ ចុះមីងគិតថាកាត់ទោសណឹងផ្តល់យុត្តិធម៌ ផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជាតិ ប្រជាជនយើងដែរ?

លាង៖ មិនដឹងយ៉ាងម៉េចទេខ្ញុំមិនសូវយល់ដែរ ។

សុជាៈ មីងយល់យ៉ាងម៉េចដែរពាក្យថាយុត្តិធម៌?

លាងៈ យុត្តិធម៌ ។

សុជាៈ មានន័យថាយ៉ាងម៉េចដែរ?

លាងៈ យុត្តិធម៌អាណឹង យើងធ្វើល្អអាណឹងយុត្តិធម៌ហើយ យើងធ្វើអំពើអាក្រក់អាណឹងមិនយុត្តិធម៌ទេ ។

សុជាៈ មីងមានអ៊ីចង់បន្ថែមទេ?

លាងៈ អត់ទេ ។

សុជាៈ អរគុណមីងច្រើនមីង?

លាងៈ ចា៎ ។

**ចប់**